# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2016, 15:05
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ការគាំទ្ររបស់លោក ខៀវ សំផន ចំពោះ "សំណើ E396 របស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកចុតហ្មាយចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្ដេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតា នរោត្តម សីហនុ"**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ូវ ឧត្តរា

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Clément BOSSIS

កញ្ញា Cécile ROUBEIX

កញ្ញា អ៊ុច ស្រីផាត

លោក តាន់ ឆាយរ័ត្ន

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដី លោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីលោក នួន ជា បានដាក់សំណើមួយធ្វើឡើង អនុលោមតាមវិធាន ៨៧ ៤) នៃវិធានផ្ទៃក្នុង ("សំណើ") ជូនអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ស្នើសុំឱ្យទទួលយកចុតហ្មាយចំនួនបីច្បាប់ និងខ្សែអាត់សម្លេង និងខ្សែវីដេអូបន្ទូលរបស់ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ[1]។

២. តាមរយៈសារណានេះ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") សូមគាំទ្រសំណើសុំនេះ។ មេធាវីការពារក្តីយល់ឃើញដូចគ្នា និងសូមគាំទ្រទឡ្ហីករណ៍ទាំងឡាយលើកឡើងដោយលោក នួន ជា ទាក់ទិននឹងលក្ខខណ្ឌនៃការទទួលយក និងភាពពាក់ព័ន្ធនៃឯកសារស្នើសុំទាំងអស់នោះ ធ្វើជាភស្តុតាង[2]។

៣. ក្នុងអំឡុងពេលចូលខ្លួនមកផ្តល់សក្ខីកម្ម លោកនរវិទូ Hinton បានវិភាគលើពាក្យ "យួន" ដោយលោកបានពន្យល់ថា ពាក្យនេះត្រូវបានពួកមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ប្រើប្រាស់ក្នុងអត្ថន័យរើសអើងពូជសាសន៍ និងប្រល័យពូជសាសន៍[3]។ បន្ទាប់មក នរវិទូរូបនេះ បានផ្តល់ជាគំនិតថា ពាក្យពេចន៍ទាំងឡាយដែលព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បានមានព្រះបន្ទូលនៅចំពោះមុខក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ កាលពីខែមករា ឆ្នាំ ១៩៧៩ ត្រូវបានប្រើប្រាស់ក្រោមសម្ពាធខ្មែរក្រហម។ ក៏ប៉ុន្តែ លោក Hinton បានបញ្ជាក់ថា លោកក៏មិនច្បាស់នឹងបញ្ហានេះដែរ[4]។

---

[1] សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ ៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកចុតហ្មាយចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតា នរោត្តម សីហនុ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E396។

[2] សំណើរបស់លោក នួន ជា ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E396 កថាខណ្ឌ ៥ និងកថាខណ្ឌ ១៨-១៩។

[3] ប្រតិចារឹកសវនាការថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/402.1 ទំព័រ ៧៩ ម៉ោងប្រហែល [១៥.៥៨.២៤]។

[4] ប្រតិចារឹកសវនាការថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/403.1 ទំព័រ ១៩ ម៉ោងប្រហែល [១០.០១.៥៣]។

## ភាពពាក់ព័ន្ធថ្មីនៃឯកសារ យោងតាមសក្ខីកម្មលោក Hinton

៤. ឯកសារទាំងឡាយស្នើសុំដោយលោក នួន ជា នាំមកនូវភ័ស្តុតាងមួយចំនួន ផ្ទុយគ្នាទៅនឹងការលើកឡើងរបស់លោក Hinton ហើយភ័ស្តុតាងទាំងនោះបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីចំណេះដឹងខ្វះចន្លោះរបស់អ្នកជំនាញរូបនេះ ពាក់ព័ន្ធនឹងបរិបទភូមិសាស្ត្រនយោបាយ នៃប្រទេសកម្ពុជាជាទូទៅ និងដោយឡែក ទាក់ទិននឹងជំហររបស់ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ។ ព្រះបន្ទូលរបស់ព្រះបរមរតនកោដ្ឋនៅក្នុងឯកសារទាំងអស់នេះ ដែលត្រូវបានគេសន្មតថាមានលក្ខណៈរើសអើងពូជសាសន៍នោះ ហាក់ដូចជាត្រូវបាននិយាយចេញមកដោយគ្មានការបង្ខិតបង្ខំបន្តិចនោះឡើយ ។ ផ្ទុយទៅវិញ ក្នុងឯកសារទាំងនោះ ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ទំនងជាអ្នកបរិហារដ៏ខ្លាំងក្លាមួយអង្គ ចំពោះឧបាយកលរបស់ប្រទេសវៀតណាម ដែលព្រះអង្គបានចាត់ទុកថាជាការប៉ះពាល់ដល់អធិបតេយ្យភាពប្រទេសរបស់ព្រះអង្គ។ ចុតហ្មាយទាំងបីច្បាប់ និងខ្សែអាត់សំឡេង និងខ្សែវីដេអូ ដែលលោក នួន ជា បានស្នើសុំឱ្យទទួលយកធ្វើជាភ័ស្តុតាង បង្ហាញឱ្យឃើញយ៉ាងច្បាស់ពីចំណុចមួយនេះ។

៥. ដូច្នេះ ភ័ស្តុតាងទាំងនេះ ពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ ក្នុងការវាយតម្លៃពីការសន្និដ្ឋានរបស់អ្នកជំនាញ ដែលផ្អែកលើព័ត៌មានមិនពេញលេញតែប៉ុណ្ណោះ។

៦. នៅទីបញ្ចប់ ក្នុងការវិភាគរបស់ខ្លួនលើព្រះបន្ទូលរបស់ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ លោក Hinton បានយោងទៅលើទស្សនៈលោក Julio JELDRES[5] ដែលជាអ្នកនិពន្ធព្រះរាជជីវប្រវត្តិ ដែលមានចុតហ្មាយទាំងបីច្បាប់ភ្ជាប់ជាមួយ។ ការទទួលយកចុតហ្មាយទាំងបីច្បាប់ គឺពិតជាមានភាពពាក់ព័ន្ធ ព្រោះថាចុតហ្មាយទាំងនោះ គឺជាភ័ស្តុតាងស៊ីសង្វាក់គ្នាជាមួយនឹងភ័ស្តុតាងមួយចំនួនទៀតដែលត្រូវបានពិភាក្សាដេញដោលរួចហើយ។

## ភាពពាក់ព័ន្ធនៃឯកសារ ទាក់ទិននឹងបរិបទប្រវត្តិសាស្ត្រ

[5] ប្រតិចារឹកសវនាការថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/403.1 ទំព័រ ១៩-២០ ម៉ោងប្រហែល [១០.០៣.៣៩]។ ការគាំទ្ររបស់លោក ខៀវ សំផន ចំពោះ "សំណើ **E396** របស់ នួន ជា អនុលោមតាមវិធាន ៨៧ ៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកចុតហ្មាយចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមកោដ្ឋ ព្រះវររាជបិតា នរោត្តម សីហនុ"

៧. ឯកសារទាំងអស់នេះ ដែលត្រូវបានស្នើសុំឲ្យទទួលយកដោយ លោក នួន ជា ក៏នាំមកផងដែរនូវធាតុផ្សំសម្រាប់ការស្វែងយល់ និងយល់ដឹងពីបរិបទនៃការប្រើប្រាស់ពាក្យមួយចំនួនក្នុងឯកសារផ្សេងៗរបស់របបកម្ពុជាប្រជាធិបតេយ្យ សម្រាប់ហៅរដ្ឋាភិបាលវៀតណាម និងបំណងប្រាថ្នាវាតទីនិយមរបស់រដ្ឋាភិបាលមួយនេះ ហើយវាបង្កើតបានជាមូលដ្ឋាននៃការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងការសន្មតថារបបកម្ពុជាប្រជាធិបតេយ្យ មានការរើសអើងពូជសាសន៍។ ឯកសារទាំងនោះ អាចផ្តល់ជាអាទិ៍នូវនិយមន័យមួយច្បាស់លាស់ និងវិសាលភាពជាក់លាក់សម្រាប់ការប្រើប្រាស់ពាក្យ "យួន" ក្នុងបរិបទពោរពេញដោយជម្លោះ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមកទៀត។

៨. ឯកសារទាំងនោះបង្ហាញពីការប្រើប្រាស់ពាក្យ "យួន" នៅក្នុងបរិបទមួយផ្សេងទៀត ខុសពីបរិបទរបបខ្មែរក្រហម ហើយឯកសារបានបង្ហាញថា ពួកខ្មែរក្រហមពុំមែនជាក្រុមតែមួយដែលបានប្រើប្រាស់ពាក្យ "យួន" នេះនោះទេ។ មេធាវីការពារក្តីផ្តោតសំខាន់ផងដែរលើការបំភ្លឺដែលមិនត្រូវមើលរំលង មាននៅក្នុងឯកសារទាំងអស់នេះ ពាក់ព័ន្ធនឹងទស្សនៈរបស់ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ចំពោះជម្លោះជាមួយប្រទេសវៀតណាម ព្រោះថាព្រះអង្គ មិនបានយាងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

៩. **<u>ផ្អែកតាមសំអាងហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះ មេត្តាសម្រេចឲ្យមេធាវីការពារក្តីចូលរួមគាំទ្រសំណើ E396 របស់លោក នួន ជា និងស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកចុតហ្លាយទាំងបីច្បាប់ ខ្សែអាត់សំឡេង និងខ្សែវីដេអូព្រះសុន្ទរកថារបស់ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ យកមកធ្វើជាភស្តុតាង។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ | |

ការគាំទ្ររបស់លោក ខៀវ សំផន ចំពោះ "សំណើ **E396** របស់ នួន ជា អនុលោមតាមវិធាន ៨៧ ៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកចុតហ្លាយចំនួនបីច្បាប់ ខ្សែវីដេអូមួយ និងខ្សែអាត់សំឡេងមួយ ទាក់ទិននឹងសម្តេចព្រះបរមកោដ្ឋ ព្រះវររាជបិតា នរោត្តម សីហនុ"